# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
## CAMBODIA WATCHDOG COUNCIL INTERNATIONAL

គ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២០

## សេចក្តីអំពាវនាវ
## កម្ពុជាធ្លាក់ក្នុងស្ថានភាពទ្វេគ្រោះ បើសិនគ្មានវិធានការជាក់លាក់ ចំពោះមេរោគកូរ៉ូណា

ខណៈពេលអាត្រាឆ្លងមេរោគកូរ៉ូណា ឬ Covid-19 បន្តរីករាលដាលកើនឡើង ដែលមិនទាន់អាចទប់ស្កាត់បាននេះ កម្ពុជាត្រូវធ្លាក់ក្នុងស្ថានភាពទ្វេគ្រោះធ្ងន់ធ្ងរ នៅពេលក្រុមពលករខ្មែររាប់ម៉ឺននាក់ ត្រឡប់ពីប្រទេសថៃ ទៅកាន់ស្រុកកំណើតវិញ ដោយមិនទាន់បានឆ្លងកាត់ធ្វើតេស្តរកមេរោគ Covid-19 មុនឬក្រោយពេលឆ្លងព្រំដែន ចូលមកកម្ពុជា។ តាមដំណឹងផ្លូវការ កម្ពុជាមកទល់ព្រឹកថ្ងៃទី ២៣ ខែមីនា ការឆ្លងមេរោគកូរ៉ូណា កើនឡើង ៨៦ នាក់ហើយ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា មានការព្រួយបារម្ភជាខ្លាំង ចំពោះលទ្ធភាពនៃការឆ្លងមេរោគកូរ៉ូណា ឬ Covid-19 កាន់តែធំទូលាយជាងមុន នៅគ្រប់ទីកន្លែង ក្នុងប្រទេសកម្ពុជា បើសិនក្រសួងសុខាភិបាល អាជ្ញាធរពាក់ព័ន្ធនានា ចាត់វិធានការដោះស្រាយគ្រោះហានីភ័យនេះ មិនទាន់សភាពការណ៍ ឬយឺតយ៉ាវ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមអំពាវនាវដល់អាជ្ញាធររដ្ឋាភិបាល ស្ថាប័នពាក់ព័ន្ធ និងពលរដ្ឋខ្មែរទាំងអស់ ត្រូវចេះសាមគ្គី បន្ថែមការយកចិត្តទុកដាក់ ការលើកទឹកចិត្ត និង រួមគ្នាទប់ស្កាត់មេរោគ Covid-19 តាមវិធីងាយៗ៖

១. អំពីសុខភាពអនាម័យ គឺត្រូវអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ឬមណ្ឌលសុខភាព នៅតាមឃុំ-សង្កាត់។

២. ពលករ ដែលទើបត្រឡប់ពីប្រទេសថៃ ត្រូវប្រញាប់ទៅពិគ្រោះជាមួយមណ្ឌលសុខភាព និង ធ្វើតេស្តរកមេរោគ Covid-19 ហើយនិង នៅក្នុងផ្ទះ ឬដាក់ខ្លួនឯងឲ្យនៅដោយឡែកពីគេ ១៤ ថ្ងៃសិន។

៣. ការជួបជុំគ្នាជាក្រុម គួរតែមិនត្រូវឲ្យច្រើនជាង ២ នាក់ទៅ ៣ នាក់ និងត្រូវរក្សាចម្ងាយពីគ្នា ពី ១ ម៉ែត្រ ទៅ ១,៥០ ម៉ែត្រ។

៤. អាជ្ញាធរឃុំ-សង្កាត់ គម្បីប្រើប្រាស់មេក្រូ ឬឧបករណ៍បំពងសម្លេង ផ្សព្វផ្សាយទៅកាន់ពលរដ្ឋ តាមភូមិឃុំ។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
ប្រធាន

ម៉ែន ណាត

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /
Hompage: https://cwcicambodia.net